# ការពារខ្លួនអ្នក និងគ្រួសាររបស់អ្នក ពីការបោកប្រាស់

## MassHealth បានប្តេជ្ញាចិត្ត ដើម្បីជួយការពារសមាជិក និងគ្រួសាររបស់គេ ពីការបោកប្រាស់។

យើងអាចនឹងទាក់ទងទៅអ្នក ឆាប់ៗនេះ អំពីការរ៉ាប់រងសុខភាពរបស់អ្នក។ MassHealth នឹងមិនដែលគំរាមកំហែងអ្នក ឬគ្រួសាររបស់អ្នក ឬសុំព័ត៌មានប័ណ្ណឥណទាន របស់អ្នកឡើយ។

**ត្រូវប្រុងប្រយ័ត្ន សំរាប់ការបោកប្រាស់!**

អ្នកបោកប្រាស់ អាចនឹងធ្វើពុត មកពីអង្គការមួយស្របច្បាប់ ឬភ្នាក់ងាររដ្ឋាភិបាលមួយ។ គេអាចប្រើទូរស័ព្ទ សារ ឬអ៊ីមែល ដើម្បីព្យាយាមលួចប្រាក់ ឬអ្វីៗមានតម្លៃពីអ្នក។

**ចូរកុំឲ្យប្រាក់ទៅអ្នកបោកប្រាស់ ឬព័ត៌មានផ្ទាល់ខ្លួន របស់អ្នកឡើយ!**




## ត្រូវដឹងអ្វីៗដើម្បីប្រុងប្រយ័ត្ន

បើសិនអ្នកទទួលទូរស័ព្ទ សារ ឬអ៊ីមែល...

- ដែលគំរាមកំហែងអ្នក ឬគ្រួសាររបស់អ្នក
- ព្រមានពីចំណាត់ការតាមច្បាប់
- ទាមទារ ឬសូមឲ្យបង់ប្រាក់ភ្លាមៗ
- តម្រូវការបង់ប្រាក់ តាមរយៈប័ណ្ណអំណោយ ប័ណ្ណឥណពន្ធបង់ប្រាក់មុន រូបិយវត្ថុអ៊ិនធឺណិត ឬតាមការផ្ញើប្រាក់តាមប្រៃសណីយ៍
- បង្ខិតបង្ខំអ្នក ដើម្បីយកព័ត៌មានផ្ទាល់ខ្លួន
- សូមការអាថ៌កំបាំង
- គំរាមកំហែង រឹបអូសយកគណនីធនាគាររបស់អ្នក ឬ
- ព្យាយាមឲ្យបានការទុកចិត្តរបស់អ្នក តាមរយៈការផ្តល់ “ឯកសារ” ដោយក្លែងបន្លំ “ភស្តុតាង” ក្លែងក្លាយ ឬឈ្មោះជាផ្លូវការពិតប្រាកដ នៃរដ្ឋាភិបាលមួយ

### វាអាចនឹងជាការបោកប្រាស់!



**បើសិនអ្នកគិតថា អ្នកបោកប្រាស់ប្រហែលជាបានទាក់ទងអ្នក សូមហៅមកយើង លេខ (800) 841-2900 (TTY: 711)**